## លិខិតប្រាប់អំពីធនធានសង្គ្រោះបន្ទាន់

ជំរាបសួរអ្នកជិតខាង ក្រុមគ្រួសារ និងមិត្តភក្តិរស់នៅ South Park ។ ពួកយើងគឺជាបុគ្គលិកនៃអង្គការអភិវឌ្ឍសៅផាក Cultivate South Park ហើយយើងចង់ប្រាប់អ្នកអំពីធនធានមួយចំនួនដែលយើងត្រូវចែករំលែកជាមួយអ្នកភ្លាមៗ។ ការិយាល័យធំរបស់យើងមានទីតាំងនៅខាងលើ Resistencia Coffee នៅផ្លូវ Cloverdale St.

មានធនធានមួយចំនួនផ្តល់ជូនលោកអ្នកនិងក្រុមគ្រួសាររបស់អ្នកដោយមិនគិតថ្លៃ៖

- មានម្ហូបអាហារដែលសមស្របតាមវប្បធម៌និងគ្រឿងទេសដែលអ្នកប្រហែលជាត្រូវការយកទៅធ្វើម្ហូបនៅផ្ទះរបស់អ្នកបរិភោគបានយ៉ាងឆ្ងាញ់។
- មានម្ហូបអាហារក្តៅក្នុងគ្រាដែលអ្នកមិនមានកន្លែងសម្រាប់ចម្អិនម្ហូបអាហារ។ យើងផ្តល់សេវាកម្មពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ខ្លះក្នុងអំឡុងខែមករាដល់ខែមីនា។ យើងក៏អាចបើកចង្ក្រានឱ្យអ្នកមកធ្វើម្ហូបដោយខ្លួនឯង ប្រសិនបើអ្នកប្រាថ្នា។
- យើងមានសំលៀកបំពាក់ស្អាតៗដែលគេប្រើរួចក្នុងករណីដែលអ្នកត្រូវការដោយសារទឹកជំនន់លិចនៅកន្លែងអ្នករស់នៅនាពេលថ្មីៗនេះ។
- ចាប់ពីសប្តាហ៍ទី 16 ដល់ថ្ងៃទី 20 ខែមករា ឆ្នាំ 2023 យើងនឹងរៀបចំផ្តល់ជូនរបស់ផ្សេងៗទៀត ដូចជារបស់របរប្រើប្រាស់ក្នុងផ្ទះ ឬអ្វីផ្សេងទៀតដែលអ្នកត្រូវការ។ យើងក៏នឹងរីករាយជួយអ្នកស្វែងរកឬតភ្ជាប់អ្នកជាមួយនឹងសេវាកម្មផ្សេងទៀត។
- សម្រាប់ក្នុងចំណោមធនធានទាំងនេះ យើងអាចផ្តល់ការដឹកជញ្ជូនទៅផ្ទះរបស់អ្នកដោយផ្ទាល់ ប្រសិនបើអ្នកបានស្នើសុំ។
- រៀងរាល់សប្តាហ៍ យើងផ្ញើសារជាអក្សរប្រាប់អំពីធនធានអ្វីខ្លះដែលអ្នកចាប់អារម្មណ៍ សូមប្រាប់យើងប្រសិនបើអ្នកចង់ឱ្យយើងបញ្ចូលលេខរបស់អ្នកទៅក្នុងប្រព័ន្ធផ្ញើសាររបស់យើង។

សូមទាក់ទងមកយើងខ្ញុំតាមវិធីដ៏ល្អបំផុតដែលអ្នកពេញចិត្ត តាមរយៈការហៅទូរស័ព្ទ ឬផ្ញើសារទៅកាន់លេខ 206-731-9937 ឬតាមរយៈអ៊ីមែល៖ monica@cultivatesouthpark.org

អ្នកក៏អាចមកកាន់កន្លែងយើងផ្ទាល់នៅ 614 S Riverside Drive, Seattle WA 98108
នៅថ្ងៃអង្គារ និងថ្ងៃសុក្រ ចន្លោះម៉ោង 10 ព្រឹកដល់ម៉ោង 2 រសៀល។